ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២១

នៅក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ ពីរាជរដ្ឋាភិបាល

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន០៤ច្បាប់

- បានធ្វើកំណត់បង្ហាញព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរណែនាំ ប្រកាស របាយការណ៍ និងលិខិតផ្សេងៗចំនួន០៤ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានតាមដានការអនុវត្តគោលនយោបាយសាធារណៈ ស្តីពី ការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាលក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- បានតាមដានអនុវត្តកម្មវិធី "ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់" ដើម្បីជួយគ្រួសារប្រជាពលរដ្ឋដែលមានកម្រិតជីវភាពទាប និងប្រឈមនឹងការលំបាកក្រោយការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ និងការផ្តល់ជំនួយជាសាច់ប្រាក់សម្រាប់អ្នកស្លាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ដោយសារជំងឺកូវីដ-១៩ និងគ្រួសារដែលមានអ្នកជំងឺកូវីដ-១៩ និងការលំបាកផ្នែកជីវភាព ក្នុងព្រឹត្តិការណ៍២០កុម្ភៈ ឆ្នាំ២០២១។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញថ្វាយបង្គំ និងសួរសុខទុក្ខ សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងសម្រាកព្យាបាលព្រះសុខភាពនៅវត្តបទុមវតីរាជវរារាម រាជធានីភ្នំពេញ, ចុះពិនិត្យការកសាងសមិទ្ធផលនានា និងនាំយកនូវទេយ្យទាន និងគ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារប្រើប្រាស់ និងថវិកាមួយចំនួនប្រគេនដល់ព្រះសង្ឃ និងគណៈកម្មការវត្ត តម្កល់ទុកបន្តកសាងវត្ត និងប្រើប្រាស់ ពិសេសសម្ភារចាំបាច់សំខាន់ៗក្នុងការរក្សាការពារ ទប់ស្កាត់បង្ការការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅខេត្តព្រៃវែង ព្រមទាំងចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយជូនរដ្ឋបាលស្រុកស្អាង និងស្រុកកោះធំ ខេត្តកណ្តាល សម្រាប់ចែកជូនប្រជាពលរដ្ឋជួបការលំបាក និងកំពុងធ្វើចត្តាឡីស័ក

- បានរៀបចំ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយគ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ សម្ភារការពារ ព្រមទាំងថវិកាមួយចំនួនឧបត្ថម្ភជូនប្រជាពលរដ្ឋមានជីវភាពខ្វះខាត និងអាជ្ញាធរមូលដ្ឋាន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុស្តិ៍រដ្ឋបាល មន្ត្រី បុគ្គលិក នៃមន្ទីរពេទ្យបង្អែកចំពោះការខិតខំប្រឹងប្រែងបំពេញការកិច្ចផ្តល់សេវាលើគ្រប់វិស័យជូនប្រជាពលរដ្ឋ ព្រមទាំងបានផ្សព្វផ្សាយ និងណែនាំអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋឱ្យអនុវត្តច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច សេចក្តីណែនាំ និងវិធានការនានារបស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាព នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពត កោះកុង ស្វាយរៀង ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ សៀមរាប ប៉ៃលិន បាត់ដំបង ឧត្តរមានជ័យ បន្ទាយមានជ័យ និងខេត្តមណ្ឌលគិរី

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុស្តិ៍នគរបាល ឈ្វេងយល់អំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ, ស្តាប់របាយការណ៍ស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ស្ថានភាព និងវិធានការគ្រប់គ្រងជំងឺកូវីដ-១៩ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ន, ក្តាប់សភាពការណ៍ទូទៅ ជាពិសេសសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងបាតុភូតធម្មជាតិ, ចុះពិនិត្យមើល

ការរៀបចំសារស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ ប្រព័ន្ធធារាសាស្ត្រ កសិដ្ឋានដាំបន្លែ និងការចិញ្ចឹមសត្វ និងលើកទឹកចិត្តឱ្យឃុំរៀបចំបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន និងគ្រប់ភូមិឱ្យបង្កើតក្រុមដោះស្រាយទំនាស់តាមសំណូមពរនានាក្នុងមូលដ្ឋាន ព្រមទាំងគោលនយោបាយផ្សេងៗលើគ្រប់វិស័យនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១០៦លើក

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បាននាំយកអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ចែកជូនប្រជាពលរដ្ឋក្រីក្រ ជួបការលំបាកខ្លាំងក្នុងតំបន់ក្រហមចំនួន១,០០០គ្រួសារ នៅសង្កាត់ស្ទឹងមានជ័យទី១ រាជធានីភ្នំពេញ, មន្ត្រីរាជការ និងកងកម្លាំងការពារសន្តិសុខសណ្តាប់ធ្នាប់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៩៩នាក់, សមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ ព្រមទាំងជូនអាហ្វាធរខណ្ឌជ្រោយចង្វារ សម្រាប់ចែកជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន៥០០គ្រួសារ ដើម្បីសម្រួលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ និងបន្តការងារសង្គមកិច្ចផ្ទៃក្នុងស្ថាប័នក្នុងបរិបទកូវីដ-១៩

- បាននាំយកអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានជំងឺកូវីដ-១៩ចំនួន០១នាក់

- បានធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០៦ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធបានចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០១ករណី

- បានផលិតទស្សនាវដ្តីប្រចាំខែឧសភា ឆ្នាំ២០២១ ចំនួន៨០០ក្បាល

- បានធ្វើលិខិតអបអរសាទរក្នុងឱកាសអបអរសាទរខួបលើកទី៦៥ នៃថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-រុស្ស៊ី

- បានធ្វើសាររំលែកទុក្ខជូនឥស្សរជននានាចំនួន០២លើក

- បានធ្វើសារលិខិតថ្វាយព្រះពរ ជូនពរ ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងពិធីខួបកំណើតថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័នផ្សេងៗចំនួន០៥លើក។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៤២ ក្រោមប្រធានបទ "យកឈ្នះពេលវេលាតានតឹងថ្ងៃនេះ និងធ្វើឱ្យប្រសើរឡើងនៅថ្ងៃស្អែក ជាតួនាទីរបស់សភា" និងកិច្ចប្រជុំ (AIPA) ព្រមទាំងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា (ASGP) តាមប្រព័ន្ធវីដេអូ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងជម្រាបលារបស់សមាជិកាព្រឹទ្ធសភាជាមួយកម្មសិក្សាការីជនជាតិបារាំង-កាណាដា

- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០១នាក់ចូលរួមវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិច ទទួលបន្ទុកសុខភាពពិភពលោក (APPFGH) តាមប្រព័ន្ធវីដេអូ

- បានចាត់ចែងផ្ញើសារលិខិតជូនលោកជំទាវប្រធានក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦៤នៃថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-រុស្ស៊ី

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន២២ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែឧសភាចំនួន០១ច្បាប់

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ទីស្តីការគណៈរដ្ឋមន្ត្រី, មជ្ឈមណ្ឌលសាន់ហ៊ាយស៍, វិទ្យាស្ថានសភាអាស៊ី(PCA), ក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បានទទួលលិខិតចូលចំនួន២៤៥ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤៦ច្បាប់

- បានសម្របសម្រួល និងយកទីតាំងក្នុងបរិវេណព្រឹទ្ធសភា ជាទីកន្លែងចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ (ដូសទី២) ជូនសម្តេច លោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ, ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារ

- បានរៀបចំតារាងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលជាប់នៅតំបន់ក្រហមចំនួន១០១នាក់ និងកំពុងធ្វើចត្តាឡីស័កចំនួន០៩នាក់

- បានធ្វើបច្ចុប្បន្នភាពផែនការអាទិភាព និងកម្មវិធីការងាររៀងៗខ្លួនឡើងវិញយោងតាមបរិបទកូវីដ-១៩ ដែលនៅបន្តបង្កើតការប្រឈមថ្មី ស្មុគស្មាញ ហើយសម្រាប់កិច្ចបន្តដំណើរការ

រួមធនធានថវិកាត្រូវមាន៥០% តិចជាងមុន និងត្រូវធ្វើវិចារណកម្មឡើងវិញទាំងស្រុងដោយផ្តោតតែលើការងារសំខាន់បំផុត ប្រញាប់បំផុត និងចាំបាច់បំផុត

- បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

- បានតាមដាន និងធ្វើបច្ចុប្បន្នភាពការប្រើប្រាស់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ របស់បណ្តាប្រទេសនានានៅលើពិភពលោកចំនួន០២ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន

- បានប្រជុំផ្ទៃក្នុងពិនិត្យការធ្វើវិចារណកម្មថវិកាឆ្នាំ២០២១របស់ព្រឹទ្ធសភាចំនួន០៣លើក

- បានប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០២១-២០២៣) និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២១

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាព្រឹទ្ធសភា៣ឆ្នាំរំកិល (២០២២-២០២៤)

- បានបើកប្រាក់បៀវត្សប្រចាំខែឧសភា និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែឧសភា ឆ្នាំ២០២១

- បានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំត្រីមាសទី១ ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំបណ្តាញប្រព័ន្ធ(FMIS) បំពាក់សម្ភារ ការប្រើប្រាស់ និងប្រជុំតាមប្រព័ន្ធវីដេអូ

- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន០៦ប័ណ្ណ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន០៥ច្បាប់

- បានប្រគល់គ្រឿងឥស្សរិយយស មេដាយការងារជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានស្នាដៃឆ្នើមសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០ ទៅតាមអគ្គនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា

- បានបើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសតាម (Zoom)

- បន្តសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ សម្រាប់ជាការិយាល័យធ្វើការរបស់នាយកដ្ឋានព័ត៌មានវិទ្យា

- បានបំពាក់តុឈើប្រជុំថ្មីបន្ថែមនៅសាលប្រជុំអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១០គ្រឿង

- បានតាំងលម្អផ្កានៅជង់ទង់ជាតិខាងមុខអគារក្រហមចំនួន០១លើក និងបានដាំផ្កាព្រះអាទិត្យចំនួន១៨០គុម្ព

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៤លើក/០៦ឫដ

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៣៧គ្រឿង/លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus និងSetup Window Printer Program Ipad ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន២៥គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៦៥ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែឧសភា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៣៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២៥ច្បាប់

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខា-

ធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១០លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាពចំនួន០៣លើក

- បានផ្ញើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១១៦ច្បាប់ ស្មើនឹង១២០នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៣៨លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៣លើក មានអ្នកចូលរួមចំនួន៥០៣នាក់

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៣សំណើ

- បានចុះសួរសុខទុក្ខមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលំហែមាតុភាព ចំនួន០១នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន៤០លីត្រ តាមការស្នើសុំរបស់អង្គភាព ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន០៦សំណើ និងចងក្រងធ្វើជាសៀវភៅចំនួន០២ក្បាល អស់ក្រដាសចំនួន៦,៦៣២សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន២៧លើក ស្មើនឹង៦៤នាក់

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែឧសភាចំនួន០៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន១,៧០០លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥២លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៣លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៣លើក។

**III-ទិសដៅការងារខែមិថុនា ឆ្នាំ២០២១**

***-បន្តចូលរួមអនុវត្តបម្រាមរាជរដ្ឋាភិបាលឱ្យម៉ឺងម៉ាត់ជាទីបំផុត ដើម្បីចូលរួមប្រយុទ្ធប្រឆាំងការរីករាលដាលជំងឺកូវីដ-១៩ តាមវិធានការរបស់ក្រសួងសុខាភិបាល។***

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៦ និងទី៧ ព្រមទាំងពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា- ឡាវ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនឆាយណា ណេស៊ិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីស្ទឹងតាតៃ លើអានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់

- បន្តធ្វើបច្ចុប្បន្នភាពរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

### ៣- មុខងារតំណាង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារ និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+ពិធីសម្ពោធសមិទ្ធផលវត្តព្រែកជ្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិវង្ស នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា

-ត្រៀមរៀបចំ និងចូលរួមប្រជុំវេទិកានានា

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) ដែលអាចចេញដំណើរក្នុងពេលឆាប់ៗនេះ ព្រោះដៃគូ SIDA ភ្នំពេញ និងបាងកក និងSDC បានចុះកិច្ចព្រមព្រៀងផ្តល់ជំនួយរួចហើយ

-បន្តតាមដានវឌ្ឍនភាពនៃការរៀបចំប្រជុំ វេទិកាសភាអន្តរជាតិនានាដូចជា ASEP11

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្រ្តថវិកាតិច សកម្មភាពច្រើន

-បន្តអនុវត្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្វែងរកជំនួយ និងការបណ្តុះបណ្តាលធនធានមនុស្សពីប្រភពដៃគូនានា និងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ IPU, APF, AIPA, ASEP...។

### ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU) ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-ត្រៀមធ្វើរបាយការណ៍ចំណូល-ចំណាយថវិកាឆមាសទី១ ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាឆ្នាំ២០២១

-ការកសាងថវិកា៣ឆ្នាំរំកិល(២០២២-២០២៤) និងថវិកាឆ្នាំ២០២២ ការកែសម្រួលការបែងចែកថវិកាជាថ្មី សម្រាប់អនុវត្តឆមាសទី២ ឆ្នាំ២០២១

-ការអនុវត្តគោលការណ៍3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាព ការអនុវត្តថវិកាឆ្នាំ២០២១ រហូតដល់ដំណាច់ឆ្នាំ ដោយផ្តោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែមិថុនា ឱ្យបានទាន់ពេលវេលា

-បន្តសហការជាមួយក្រុមការងារ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់ និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការបណ្តុះបណ្តាលទីងមានសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងបរិបទកូវីដ-១៩នេះ និងឆ្នាំខាងមុខ ហើយអាចសម្រេចយុទ្ធសាស្ត្រកៀរគរជំនួយ DO MORE WITH LESS ឬ LESS IS MORE ក្នុងក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា (២០២១-២០៣០)

-បន្តបណ្តុះបណ្តាលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមកម្មវិធីរៀនពីចម្ងាយ

-បន្តការដ្ឋានសំណង់អគារកម្ពស់៣ជាន់ និងសិក្សាកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង និងការគ្រប់គ្រងការប្រើប្រាស់ Internet

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗល។)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យជាតិសំខាន់ៗ៖ ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។

IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែឧសភានេះ ទោះបីប្រទេសជាតិយើងកំពុងបន្តប្រឈមនឹងជំងឺកូវីដ-១៩ ក្តីការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ នៅតែជាហានិភ័យនៅឡើយ ដែលនាំឱ្យផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាតិយើងទាំងមូល។ ស្របពេលជាមួយគ្នានេះ ព្រឹទ្ធសភានៅតែខិតខំបន្តបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មតាមបែបគន្លងថ្មី ដោយផ្តោតការយកចិត្តទុកដាក់លើមុខងារតំណាង ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។ ជាមួយគ្នានេះដែរ លើមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានខិតខំយ៉ាងសកម្មក្នុងការរៀបចំ និងចាត់ចែងការចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភា(IPU) លើកទី១៤២ និងចូលរួមកិច្ចប្រជុំ(AIPA) និង (ASGP) តាមប្រព័ន្ធវីដេអូ។

ដើម្បីឱ្យស្របតាមបរិបទនៃការវិវត្តថ្មី ជាពិសេសការធ្វើវិចារណកម្មថវិកាឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ខិតខំពង្រឹងប្រសិទ្ធភាពចំណាយ ដោយអនុវត្តគោលការណ៍3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពការអនុវត្តថវិកាឆ្នាំ២០២១ រហូតដល់ដំណាច់ឆ្នាំ ដោយផ្តោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត។

ព្រឹទ្ធសភានឹងចាប់ផ្តើមសម័យប្រជុំព្រឹទ្ធសភា លើកទី៧ នីតិកាលទី៤ ក្នុងពេលខាងមុខដ៏ខ្លីនេះ។

មន្ត្រីរាជការទាំងអស់ ត្រូវអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល

ឱ្យបានម៉ឺងម៉ាត់ ព្រមទាំងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។ ជំងឺកូវីដ-១៩ នៅបន្តជាការគំរាមកំហែងរួមសម្រាប់ពេលខាងមុខនេះ។

ថ្ងៃ[illegible] ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ២០២១

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ